ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

# បច្ចុប្បន្នភាព
# ស្តង់ដាទីក្រុងស្អាត
# Clean City Standard

បោះពុម្ពឆ្នាំ ២០២១

# មាតិកា

I. ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/ ចុះថ្ងៃទី២៤ មិថុនា ឆ្នាំ២០១១ ស្ដីពី ការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

II. បច្ចុប្បន្នភាពស្តង់ដាទីក្រុងស្អាត

III. សេចក្ដីសម្រេចស្ដីពីការកែសម្រួលសូចនាករ និងលក្ខណវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
ចូល លេខ: 1542 ......របកម
ម៉ោង 10 25 ថ្ងៃទី 3/6/11
បញ្ជូនទៅ:........................
អ្នកទទួល:........................

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៦១៤

## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ដែលសរសេរអក្សរកាត់ថា **គ.ជ.វ.ទ.** ដើម្បីវាយតម្លៃទីក្រុងស្អាត តាមរយៈការប្រឡងប្រណាំង ក្នុងគោលបំណងលើកកម្ពស់សោភ័ណភាព អនាម័យ បរិស្ថានល្អនៅតាមបណ្តាទីក្រុង ពិសេសចូលរួមធ្វើឱ្យទីក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្លាយជាគោលដៅទេសចរណ៍ ដែលទាក់ទាញ និងប្រកបដោយភាពកក់ក្តៅ។

## ជំពូកទី២
## សមាសភាព

**មាត្រា ២.-**

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន | ០១ រូប | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - ប្រធានគណៈកម្មការគ្រប់គ្រង អភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្តទាំង២៤ | | សមាជិក |
| - អគ្គលេខាធិការគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់ **គ.ជ.វ.ទ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ គ.ជ.ទ.ឆ.

**មាត្រា ៣.-**

**គ.ជ.ទ.ឆ.** មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- អនុវត្តយុទ្ធនាការអប់រំ និងផ្សព្វផ្សាយជាសាធារណៈ អំពីការប្រឡងប្រណាំងទីក្រុងស្អាត
- កំណត់ទម្រង់ និងបែបបទនៃការចុះឈ្មោះ ក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំនិងដាក់ឱ្យដំណើរការ ការប្រឡងប្រណាំងទីក្រុងស្អាត
- វាយតម្លៃទីក្រុងស្អាត ដោយផ្អែកលើស្តង់ដារទីក្រុងស្អាត ដែលជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ
- ចេញស្លាកសញ្ញាផ្លូវការឱ្យទីក្រុងដែលជាជ័យលាភី
- ពិនិត្យនិងតាមដាន ការអនុវត្តរបស់ទីក្រុងជ័យលាភី ក្រោយទទួលបានស្លាកសញ្ញាពី **គ.ជ.ទ.ឆ.**
- ផ្តល់អនុសាសន៍និងណែនាំដល់ទីក្រុងបេក្ខភាព ដែលពុំទាន់បានឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យ ក្នុងស្តង់ដារទីក្រុងស្អាត
- ដកហូតស្លាកសញ្ញា ពីទីក្រុងជ័យលាភីទាំងឡាយណា ដែលបាត់បង់ ឬមិនគោរពតាមលក្ខណៈវិនិច្ឆ័យ នៃស្តង់ដារទីក្រុងស្អាត
- រៀបចំនិងធ្វើបច្ចុប្បន្នភាព លើសូចនាករនិងនីតិវិធី ក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការជាមួយនឹងក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើ ឱ្យកាន់តែមានប្រសិទ្ធភាព
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ជ.ទ.ឆ.

**មាត្រា ៤.-**

**គ.ជ.ទ.ឆ.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៥.-**

**គ.ជ.ទ.ឆ.** អាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំ ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងក្របខណ្ឌការងាររបស់ខ្លួន។

មាត្រា ៦.-

បែបបទនិងនីតិវិធីការងាររបស់ គ.ជ.ទ.ឆ. ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ទ.ឆ.។

មាត្រា ៧.-

គ.ជ.ទ.ឆ. អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួន តាមការចាំបាច់។

មាត្រា ៨.-

គ.ជ.ទ.ឆ. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលត្រូវមានទីតាំងស្ថិតនៅក្នុងក្រសួងទេសចរណ៍។

មាត្រា ៩.-

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ទ.ឆ. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ទ.ឆ. ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ១០.-

គ.ជ.ទ.ឆ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥

## ប្រភពធនធាន

មាត្រា ១១.-

គ.ជ.ទ.ឆ. មានប្រភពធនធានផ្គត់ផ្គង់ដោយកញ្ចប់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍ និងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ព្រមទាំងប្រភពស្របច្បាប់ផ្សេងទៀតសម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

មាត្រា ១២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១១

ពរល. ១១០៦. ៦២៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខ: ៥៩១ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១១

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ :** ១២០ សជណ.៣១

ថ្ងៃពុធ ១៣កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិ**
**វាយតម្លៃទីក្រុងស្អាត**

**កម្មវត្ថុ៖** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ រៀបចំចលនាប្រឡងប្រណាំងទីក្រុងស្អាតលើកទី៣ សម្រាប់សុពលភាព (២០២១-២០២៤)។

**យោង ៖**
- លិខិតលេខ០០៧ ល.ស.គជវ១ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលយល់ព្រមជាគោលការណ៍ដូចខាងក្រោម៖

១. ឱ្យរៀបចំចលនាប្រឡងប្រណាំងទីក្រុងស្អាតលើកទី៣ សុពលភាពឆ្នាំ២០២១-២០២៤ សម្រាប់ក្រុង-ខណ្ឌគោលដៅចំនួន ៤១ ដោយប្រើប្រាស់នូវស្តង់ដាទីក្រុងស្អាតថ្មី ស្របតាមបទប្បញ្ញត្តិទូទៅនៃការប្រឡងប្រណាំងទីក្រុងស្អាតលើកទី៣ (២០២១-២០២៤)។

២. អនុញ្ញាតឱ្យក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី-ខេត្ត ត្រូវដឹកនាំដោយឯកឧត្តម ឬលោកជំទាវអភិបាលរាជធានី-ខេត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**កែន សត្ថា**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

# ស្តង់ដាទីក្រុងស្អាត

ឆ្នាំ២០២១

# មាតិកា


**សេចក្តីផ្តើម** ........................................ ១

**I. សូចនាករនៃការវាយតម្លៃទីក្រុងស្អាត** ........................................ ៣

១. សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន(មាន៨សូចនាករលម្អិត) .................... ៣

២. សូចនាករគោលនៃភាពស្អាត(មាន៦សូចនាករលម្អិត) .................... ៤

៣. សូចនាករគោលនៃការគ្រប់គ្រងសំណល់ (មាន៥សូចនាករលម្អិត) .................... ៦

៤. សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង(មាន៤សូចនាករលម្អិត) .................... ៧

៥. សូចនាករគោលនៃតំបន់បៃតង និងខ្សែក្រវាត់បៃតង (មាន៧សូចនាករលម្អិត) .................... ៨

៦. សូចនាករគោលនៃសុវត្ថិភាពសុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង (មាន៥សូចនាករលម្អិត) .................... ៩

៧. សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ (មាន៦សូចនាករលម្អិត) .................... ១១

**II. យន្តការនៃការប្រឡងប្រណាំងទីក្រុងស្អាត** .................... ១៣

**III. ដំណើរការនៃការប្រឡងប្រណាំង** .................... ១៤

## **សេចក្តីផ្តើម**

ស្តង់ដាទីក្រុងស្អាតត្រូវបានធ្វើបច្ចុប្បន្នភាព ដោយកែសម្រួលនូវសូចនាករ និងលក្ខណវិនិច្ឆ័យទៅតាមស្ថានភាពជាក់ស្តែង នៃចលនាប្រឡងប្រណាំងទីក្រុងស្អាត។ បច្ចុប្បន្នភាពនៃស្តង់ដាទីក្រុងស្អាតមាន៧ សូចនាករគោលចំនួន **៤១** សូចនាករលម្អិត និងមាន **១១៣** លក្ខណវិនិច្ឆ័យ(ស្មើនឹង**១២០** ពិន្ទុ) មានដូចខាងក្រោម៖

- មាន ៨ សូចនាករលម្អិតនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន ៖ ១៤ លក្ខណវិនិច្ឆ័យ( ស្មើនឹង១៤ពិន្ទុ)
- មាន ៦ សូចនាករលម្អិតនៃភាពស្អាត ៖ ២៣ លក្ខណវិនិច្ឆ័យ (ស្មើនឹង ២៥ ពិន្ទុ)
- មាន ៥ សូចនាករលម្អិតនៃការគ្រប់គ្រងសំណល់ ៖ ១១ លក្ខណវិនិច្ឆ័យ (ស្មើនឹង ១១ ពិន្ទុ)
- មាន ៤ សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹង ៖ ១០ លក្ខណវិនិច្ឆ័យ (ស្មើនឹង ១០ ពិន្ទុ)
- មាន ៧ សូចនាករលម្អិតនៃតំបន់បៃតង និងខ្សែក្រវាត់បៃតង ៖ ១៧ លក្ខណវិនិច្ឆ័យ (ស្មើនឹង ១៨ ពិន្ទុ)
- មាន ៥ សូចនាករលម្អិតនៃសុវត្ថិភាពសុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង៖ ១៩ លក្ខណវិនិច្ឆ័យ (ស្មើនឹង ២១ ពិន្ទុ)
- មាន ៦ សូចនាករលម្អិតនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ ៖ ១៩ លក្ខណវិនិច្ឆ័យ (ស្មើនឹង ២១ ពិន្ទុ)

I. **តារាងសូចនាករនៃការវាយតម្លៃទីក្រុងស្អាត**

១. <u>សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន (មាន៨សូចនាករលម្អិត)</u>

| សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-**E1** សូចនាករលម្អិតនៃការរៀបចំទីក្រុង | ប្លង់គោលប្រើប្រាស់ដីក្រុង | មាន-មិនមាន | ១ |
| | ផែនការប្រើប្រាស់ដីក្រុង | មាន-មិនមាន | ១ |
| | គម្រោងអភិវឌ្ឍក្រុង | មាន-មិនមាន | ១ |
| ២-**E2** សូចនាករលម្អិតនៃលិខិតបទដ្ឋានគតិយុត្តស្ដីអំពីបរិស្ថាន | យន្តការដែលអាចដាក់ទណ្ឌកម្មដោយអាជ្ញាធរ មូលដ្ឋាន (ការពិន័យជាប្រាក់ ឬការបិទអាជីវកម្ម) ចំពោះ ការមិនគោរព និងមិនចូលរួមថែរក្សាបរិស្ថាន (ដូចជា ការបញ្ចេញសំណល់ឥតសណ្ដាប់ធ្នាប់ ការមិនគោរពបទប្បញ្ញត្តិនគរូបនីយកម្ម។ល។) | មាន-មិនមាន | ១ |
| ៣-**E3** សូចនាករលម្អិតនៃគុណភាពទឹក | ការត្រួតពិនិត្យលើភាពស្អាតរបស់ទឹក (ទន្លេ ស្ទឹង សមុទ្រ) | មាន-មិនមាន | ១ |
| | ការត្រួតពិនិត្យលើភាពស្អាតរបស់ទឹកសម្រាប់ បរិភោគ | មាន-មិនមាន | ១ |
| ៤-**E4** សូចនាករលម្អិតនៃគុណភាពខ្យល់ | វិធានការដែលទាក់ទងទៅនឹងគុណភាពខ្យល់ (ឧទាហរណ៍៖គម្រោងនៃការកាត់បន្ថយការស្ទះចរាចរណ៍ ផ្លូវថ្មើរជើង "Pesdestrian" ។ល។) | មាន-មិនមាន | ១ |
| | វិធានការដែលទាក់ទងទៅនឹងបរិស្ថានគ្មានផ្សែងបារី | មាន-មិនមាន | ១ |
| ៥-**E5** សូចនាករលម្អិតនៃការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង | វិធានការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង (សម្លេងមីក្រូ ខារ៉ាអូខេ។ល។) | មាន-មិនមាន | ១ |
| ៦-**E6** សូចនាករលម្អិតនៃដៃគូសហប្រតិបត្តិការ | ដៃគូសហប្រតិបត្តិការ (ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងសហប្រតិបត្តិការក្នុងតំបន់ដែលទាក់ទងនឹងការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាន ភាពស្អាត ឬការគ្រប់គ្រងសំណល់) | មាន-មិនមាន | ១ |
| ៧-**E7** សូចនាករលម្អិតនៃការធ្វើដំណើរដែលគិតគូរដល់បរិស្ថាន | មធ្យោបាយធ្វើដំណើរដែលលើកទឹកចិត្តដល់ការគិតគូរពីបរិស្ថាន (ឧទាហរណ៍៖ ដូចជា រថយន្តក្រុង រថយន្តធ្វើដំណើរដោយថាមពលអគ្គិសនី ផ្លូវថ្មើរជើង ផ្លូវជិះកង់ ។ល។) | មាន-មិនមាន | ១ |
| | សកម្មភាពនិងវិធានការលើកទឹកចិត្តដល់សម្បទាទេសចរណ៍ (សេវាកម្មស្នាក់នៅ ភោជនីយដ្ឋាន និង | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | សេវាកម្មទេសចរណ៍ផ្សេងទៀត) និងប្រជាពលរដ្ឋឱ្យប្រើប្រាស់ថាមពលដែលកកើតឡើងវិញ (Renewable Energy) | | |
| ៨-**E8** សូចនាករលម្អិតនៃការប្រើប្រាស់ថាមពលដែលគិតគូរដល់បរិស្ថាន | ភាគរយនៃការប្រើប្រាស់ថាមពលដែលកកើតឡើងវិញនៅតាមសម្បទាទេសចរណ៍(សេវាកម្មស្នាក់នៅ ភោជនីយដ្ឋាន និងសេវាកម្មទេសចរណ៍ផ្សេងទៀត) | យ៉ាងហោចណាស់មាន ៣០%នៃចំនួនសម្បទាទេសចរណ៍សរុបក្នុងទីក្រុង | ១ |
| | សកម្មភាព និងវិធានការលើកទឹកចិត្តដល់សម្បទាទេសចរណ៍ (សេវាកម្មស្នាក់នៅ ភោជនីយដ្ឋាន និងសេវាកម្មទេសចរណ៍ផ្សេងទៀត) និងប្រជាពលរដ្ឋក្នុងការសន្សំសំចៃការប្រើប្រាស់ថាមពល (Efficient Energy use) (ឧទាហរណ៍ ការប្រើប្រាស់អំពូលស៊ីថាមពលតិច ការប្រើប្រាស់សោរផ្តាច់អគ្គិសនីដោយស្វ័យប្រវត្តិតាមសណ្ឋាគារ។ល។) | មាន-មិនមាន | ១ |
| **- ចំនួនសូចនាករលំអិត ៖ ៨<br>- ចំនួនលក្ខណៈវិនិច្ឆ័យ ៖ ១៤** | | **សរុប** | **១៤** |

## ២. <u>សូចនាករគោលនៃភាពស្អាត (មាន៦សូចនាករលម្អិត)</u>

| **សូចនាករគោលនៃភាពស្អាត** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ៩-**P1** សូចនាករលម្អិតនៃភាពស្អាតនៅទីកន្លែងសាធារណៈ | ភាពស្អាតនៅតាមកន្លែងសំខាន់ៗ ដែលអាចជាកន្លែងទទួលសាធារណៈជន ដូចជា ការិយាល័យរដ្ឋបាលសាធារណៈ តំបន់បៃតង ទីស្នាក់ការព័ត៌មាន ទីផ្សារសំខាន់ៗ និងវិថីលក់ម្ហូបអាហារ | មាន-មិនមាន | ១ |
| | តើកន្លែងទាំងនោះ គឺជាកម្មវត្ថុនៃការថែរក្សា និងសម្អាតយ៉ាងទៀតទាត់ឬទេ? | យ៉ាងហោច១ដងក្នុង១ថ្ងៃ | ១ |
| | មានធុងសំរាមគ្រប់គ្រាន់នៅតាមទីកន្លែងសាធារណៈសំខាន់ៗ | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមសាលារៀន | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមវត្តអារាម | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមផ្សារ | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមរោងចក្រ | មាន-មិនមាន | ១ |
| | មានបង្គន់សាធារណៈនៅតាមទីកន្លែងសាធារណៈ | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| **១០-P2** សូចនាករលម្អិតនៃភាពស្អាតនៅតាមបង្គន់សាធារណៈ | ភាពស្អាតនៅតាមបង្គន់សាធារណៈទាំងនោះ | មាន-មិនមាន | ១ |
| | បង្គន់សាធារណៈទាំងនោះជាកម្មវត្ថុនៃការថែរក្សា និងសម្អាតយ៉ាងទៀងទាត់ | យ៉ាងហោច ៤ដងក្នុង១ថ្ងៃ | ២ |
| **១១-P3** សូចនាករលម្អិតនៃភាពស្អាតនៅតាមគោលដៅទេសចរណ៍ និងសម្បទាទេសចរណ៍ (សារមន្ទីរ ប្រាសាទ សួនកំសាន្ត ផ្សារ) | ភាពស្អាតនៅតាមគោលដៅទេសចរណ៍ (រមណីយដ្ឋាន និងសម្បទាទេសចរណ៍) | មាន-មិនមាន | ១ |
| | កន្លែងទាំងនោះគឺជាកម្មវត្ថុនៃការថែរក្សា និងសម្អាតយ៉ាងទៀងទាត់គឺ | យ៉ាងហោច ២ដងក្នុង១ថ្ងៃ | ១ |
| | មានធុងសំរាមគ្រប់គ្រាន់នៅតាមគោលដៅទេសចរណ៍ (រមណីយដ្ឋាន និងសម្បទាទេសចរណ៍) | មាន-មិនមាន | ១ |
| | មានបង្គន់សាធារណៈនៅតាមគោលដៅទេសចរណ៍ (រមណីយដ្ឋាន និងសម្បទាទេសចរណ៍) | មាន-មិនមាន | ១ |
| | ភាគរយនៃភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ដែលបានចូលរួមអនុវត្តយុទ្ធនាការ "ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ស្អាត (Green Passport) " | យ៉ាងហោចណាស់ ៥០% | ២ |
| **១២-P4** សូចនាករលម្អិតនៃភាពស្អាតនៅតាមទីកន្លែង និងដងវិថីសំខាន់ៗ | ភាពស្អាតនៅតាមកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់នៅក្នុងទីក្រុង | មាន-មិនមាន | ១ |
| | កន្លែងទាំងនោះគឺជាកម្មវត្ថុនៃការសម្អាតជាប្រចាំ | យ៉ាងហោច ២ដងក្នុង១ថ្ងៃ | ១ |
| | តើមានធុងសំរាមគ្រប់គ្រាន់នៅតាមទីកន្លែងទាំងនោះដែរឬទេ? | មាន-មិនមាន | ១ |
| | ការគ្រប់គ្រងលើអាកប្បកិរិយា និងការកំណត់អំពីការស្លៀកពាក់របស់អ្នកបើកបររថយន្តឈ្នួល រ៉ឺម៉កកង់បី ម៉ូតូឌុប និងអ្នកដំណើរទាំងឡាយនៅលើដងវិថីសាធារណៈ | មាន-មិនមាន | ១ |
| **១៣-P5** សូចនាករលម្អិតនៃភាពស៊ីគ្នានៃស្ថាបត្យកម្មរបស់តំបន់ដែលជាអគារសាធារណៈ និងផ្ទះរបស់ប្រជាពលរដ្ឋ | ភាពស៊ីសង្វាក់គ្នានៃរចនាបថរបស់អគារសាធារណៈ | មាន-មិនមាន | ១ |
| | ភាពស៊ីសង្វាក់គ្នានៃរចនាបថរបស់លំនៅដ្ឋានប្រជា-ពលរដ្ឋ។ | មាន-មិនមាន | ១ |
| **១៤-P6** សូចនាករលម្អិតនៃការតុបតែងលំអនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ | ភាពស៊ីសង្វាក់គ្នានៃការតុបតែងលំអនៅតាមទីរមណីយដ្ឋាននានាស្របទៅនឹងលក្ខណៈពិសេសនៃតំបន់នីមួយៗ (*Spécificité de la région*) | មាន-មិនមាន | ១ |
| | ភាពស៊ីសង្វាក់គ្នានៃការតុបតែងលំអមធ្យោបាយដឹកជញ្ជូនទេសចរណ៍ | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៦**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ២៣** | | **សរុប** | **២៥** |

## ៣. សូចនាករគោលនៃការគ្រប់គ្រងសំណល់ (មាន៥សូចនាករលម្អិត)

| សូចនាករគោលនៃការគ្រប់គ្រងសំណល់ | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **១៥-D1** សូចនាករលម្អិតនៃការប្រមូលសំណល់រាវ | ភាគរយនៃប្រជាពលរដ្ឋដែលតភ្ជាប់ទៅនឹងបណ្ដាញលូបង្ហូរទឹកកខ្វក់ | យ៉ាងហោចណាស់មាន៣០%ដែលមានការតភ្ជាប់ | ១ |
| | ភាពញឹកញាប់នៃការថែទាំ ឬត្រួតពិនិត្យជួសជុលបណ្ដាញលូបង្ហូរទឹកកខ្វក់ | យ៉ាងហោច២ដងក្នុង១ឆ្នាំ | ១ |
| **១៦-D2** សូចនាករលម្អិតនៃការប្រមូលសំណល់រឹង | ភាគរយនៃប្រជាពលរដ្ឋដែលស្ថិតនៅក្នុងការប្រមូលសំណល់រឹងជាទៀងទាត់ | អប្បបរមា៥០% | ១ |
| | ភាពញឹកញាប់នៃការប្រមូលសំណល់រឹង | យ៉ាងហោច១ដងក្នុង១ថ្ងៃ | ១ |
| **១៧-D3** សូចនាករលម្អិតអំពីការស្ដុក និងការធ្វើប្រព្រឹត្តកម្មលើសំណល់រាវ | លទ្ធភាពដែលអាចស្ដុកសំណល់រាវ (មានអាងស្ដុកសំណល់រាវ) | មាន-មិនមាន | ១ |
| | ចំនួនភាគរយនៃសណ្ឋាគារ និងផ្ទះសំណាក់ដែលមានអាងស្ដុកសម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់រាវ | អប្បបរមា៥០% | ១ |
| **១៨-D4** សូចនាករលម្អិតនៃការស្ដុក និងការធ្វើប្រព្រឹត្តកម្មលើសំណល់រឹង | លទ្ធភាពដែលអាចស្ដុកសំណល់រឹង ក្រៅអំពីការស្ដុកចោលដោយគ្មានការការពារឱ្យបានត្រឹមត្រូវ (ឧទាហរណ៍ ការស្ដុកសំណល់រឹងដោយមានការជីកកប់ឱ្យបានត្រឹមត្រូវ) | មាន-មិនមាន | ១ |
| | ទីកន្លែងកែច្នៃសំណល់រឹង ដោយរដ្ឋ ឬឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល ។ល។ | មាន-មិនមាន | ១ |
| **១៩-D5** សូចនាករលម្អិតនៃការបែងចែកសំណល់រឹង | លទ្ធភាពដែលអាចឱ្យសហគ្រាសទាំងឡាយ និង/ឬប្រជាជនមូលដ្ឋានអាចធ្វើការបែងចែកសំណល់រវាងសំណល់ធម្មតានិងសំណល់ដែលមានជាតិពុល(ថ្មពិល អាគុយ ប្រេងដែលប្រើប្រាស់រួច។ល។) | មាន-មិនមាន | ១ |
| | ការបំពាក់ធុងសំរាមដែលមានការបែងចែកប្រភេទសំរាម (ទីតាំងសាធារណៈ លំនៅដ្ឋានប្រជាពលរដ្ឋ។ល។) | មាន-មិនមាន | ១ |
| | រថយន្តប្រមូលសំរាមដែលមានការបែងចែកប្រភេទសំរាម | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៥**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១១** | | **សរុប** | **១១** |

## ៤. សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង (មាន៤សូចនាករលម្អិត)

| សូចនករគោល នៃការបញ្ជ្រាបការយល់ដឹង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **២០-I1** សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ប្រជាជនមូលដ្ឋាន | សកម្មភាពក្នុងការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ ប្រជាជនមូលដ្ឋាន | មាន-មិនមាន | ១ |
| | ភាពញឹកញាប់នៃសកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ប្រជាជនមូលដ្ឋាន | យ៉ាងហោច ២ដងក្នុង១ឆ្នាំ | ១ |
| | មធ្យោបាយបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាន និងភាពស្អាត(បដាព័ត៌មាន ខិតប័ណ្ណផ្សព្វផ្សាយ ។ល។) | មាន-មិនមាន | ១ |
| **២១-I2** សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍ | ឯកសារផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដែលឯកសារទាំងនោះធ្វើឡើងសំដៅដល់ប្រតិបត្តិករទេសចរណ៍ទាំងឡាយ (កូនសៀវភៅការ ណែនាំ ។ល។) | មាន-មិនមាន | ១ |
| | ភាពញឹកញាប់នៃសកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍ | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| **២២-I3** សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ភ្ញៀវទេសចរ | មធ្យោបាយបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាន និងភាពស្អាត (បដាព័ត៌មាន ខិតប័ណ្ណផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹង ។ល។) | មាន-មិនមាន | ១ |
| | សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតធ្វើឡើងដោយប្រតិបត្តិករទេសចរណ៍នៅតាមគោលដៅទាក់ទាញទេសចរណ៍ | មាន-មិនមាន | ១ |
| **២៣-I4** សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់កម្មករ-កម្មការនីរោងចក្រ ឬសហគ្រាស | សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់កម្មករ-កម្មការនីរោងចក្រ ឬសហគ្រាស | មាន-មិនមាន | ១ |
| | ភាពញឹកញាប់នៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់កម្មករ-កម្មការនី រោងចក្រ ឬសហគ្រាស | យ៉ាងហោច ២ដងក្នុង១ឆ្នាំ | ១ |
| | មធ្យោបាយបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាន និងភាពស្អាត(បដាព័ត៌មាន ខិតប័ណ្ណផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹង ។ល។) | មាន-មិនមាន | ១ |
| - **ចំនួនសូនាករលំអិត ៖ ៤**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១០** | | សរុប | ១០ |

## ៥. សូចនាករគោលនៃតំបន់បៃតង និងខ្សែក្រវាត់បៃតង( មាន៧សូចនាករលម្អិត )

| សូចនករគោលនៃតំបន់បៃតង និងខ្សែក្រវាត់បៃតង | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **២៤-V1** សូចនាករលម្អិតនៃការបង្កើត និងបែងចែកតំបន់បៃតង | ភាគរយតំបន់បៃតងធៀបនឹងផ្ទៃក្រឡាទីក្រុងទាំងមូល | ធំជាង ៥% | ២ |
| | សួនទេសចរណ៍នៅក្នុងទីក្រុង-ខណ្ឌ ឬតំបន់ជុំវិញ | មាន-មិនមាន | ១ |
| **២៥-V2** សូចនាករលម្អិតនៃការថែទាំ និងរៀបចំតំបន់បៃតង | លើកកម្ពស់សោភណ្ឌភាពតំបន់បៃតងដែលមានស្រាប់ (ការដាក់ភ្លើងបំភ្លឺ កៅអីសាធារណៈ ផ្លូវដើរ ។ល។) | មាន-មិនមាន | ១ |
| | ភាពញឹកញាប់ក្នុងការថែទាំតំបន់បៃតង | យ៉ាងហោច ៣ដងក្នុង ១សប្តាហ៍ | ១ |
| | ភាពញឹកញាប់ក្នុងការរៀបចំកម្មវិធីដាំដើមឈើ | យ៉ាងហោច ៤ដងក្នុង១ឆ្នាំ | ១ |
| **២៦-V3** សូចនាករលម្អិតនៃការគ្រប់គ្រងតំបន់បៃតង | ការគិតគូរអំពីលក្ខខណ្ឌបរិស្ថានក្នុងការគ្រប់គ្រងតំបន់បៃតង (ការជ្រើសរើសទីតាំង វិធីស្រោចទឹក ការប្រើប្រាស់ជីកំប៉ុស្ត៍។ល។) | មាន-មិនមាន | ១ |
| **២៧-V4** សូចនាករលម្អិតនៃការរៀបចំទីតាំងលក់ផលិតផលក្នុងស្រុក | ផ្សារ ឬផ្សាររាត្រី ឬហាងដែលលក់ផលិតផលក្នុងស្រុក | មាន-មិនមាន | ១ |
| | មានការតាំងពិព័រណ៍អំពីផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| **២៨-V5** សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងអំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ប្រតិបត្តិករទេសចរណ៍អំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់សាធារណជនអំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ទេសចរជាតិ និងអន្តរជាតិពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| **២៩-V6** សូចនាករលម្អិតនៃការរៀបចំខ្សែក្រវាត់បៃតង | ដៃគូសហប្រតិបត្តិការ ( ដូចជា អង្គការជាតិ-អន្តរជាតិ រដ្ឋាភិបាល ផ្នែកឯកជន សហគមន៍មូលដ្ឋាន ។ល។) ក្នុងការរៀបចំខ្សែក្រវាត់បៃតងនៅតាមគោលដៅទេសចរណ៍ និងតំបន់ជុំវិញទីក្រុង | មាន-មិនមាន | ១ |
| | បណ្តាញអ្នកប្រមូលទិញ ឬអន្តរការី ដើម្បីជំរុញឲ្យមានការប្រើប្រាស់ផលិតផលក្នុងស្រុក | មាន-មិនមាន | ១ |
| | សមាគម ឬសហគមន៍កសិកម្ម និងសិប្បកម្មដែលមានការផ្គត់ផ្គង់សម្រាប់វិស័យទេសចរណ៍ | មាន-មិនមាន | ១ |
| | ដៃគូសហប្រតិបត្តិការក្នុងការរៀបចំខ្សែទស្សនកិច្ច | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | កសិ-ទេសចរណ៍នៅតាមគោលដៅតំបន់ជុំវិញទីក្រុង | | |
| **៣០-V7** សូចនាករលម្អិតនៃការជំរុញការប្រើប្រាស់ និងផលិតផលិតផលក្នុងស្រុក | វិធានការជំរុញ និងលើកទឹកចិត្តដល់អ្នកប្រើប្រាស់ផលិតផលក្នុងស្រុក (ពិសេសសម្រាប់ប្រតិបត្តិករទេសចរណ៍) | មាន-មិនមាន | ១ |
| | វិធានការជំរុញ និងលើកទឹកចិត្តដល់អ្នកផលិតផលិតផលក្នុងស្រុកដែលផ្គត់ផ្គង់វិស័យទេសចរណ៍ | មាន-មិនមាន | ១ |
| **- ចំនួនសូចនាករលំអិត ៖ ៧**<br>**- ចំនួនលក្ខណវិនិច្ឆ័យ ៖ ១៧** | | **សរុប** | **១៨** |

## ៦. <u>សូចនាករគោលនៃសុវត្ថិភាពសុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង (មាន៥សូចនាករលម្អិត)</u>

| **សូចនាករគោលនៃសុវត្ថិភាពសុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង** | **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| **៣១-S1** សូចនាករលម្អិតនៃសុវត្ថិភាពសុខភាពសាធារណៈ | មានមណ្ឌលសុខភាពគ្រប់គ្រាន់ | យ៉ាងហោច ១ក្នុង១សង្កាត់ | ១ |
| | លទ្ធភាពនៃការត្រួតពិនិត្យអនាម័យតាមភោជនីយដ្ឋាន (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោច ៣ដង ក្នុង១ខែ | ១ |
| | លទ្ធភាពនៃការត្រួតពិនិត្យអនាម័យតាមផ្សារលក់ចំណី អាហារ (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោច ៣ដង ក្នុង១ខែ | ១ |
| | លទ្ធភាពនៃការត្រួតពិនិត្យអនាម័យរបស់អ្នកលក់ដូរចល័ត (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោច ៣ដង ក្នុង១ខែ | ១ |
| | ភាគរយអាជីវកម្មដែលមានលិខិតបញ្ជាក់ពីក្រសួង ឬមន្ទីរសុខាភិបាល | យ៉ាងហោច ៧០% | ១ |
| **៣២-S2** សូចនាករលម្អិតនៃសន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង | តើមន្ត្រីនគរបាលទេសចរណ៍មានចំនួនគ្រប់គ្រាន់ដែរឬទេបើធៀបនឹងចំនួនទេសចរ? | មាន-មិនមាន | ១ |
| | ភាគរយមន្ត្រីនគរបាលទេសចរណ៍ដែលបានទទួលការហ្វឹកហ្វាត់ជំនាញ (ភាសា និងការទទួលភ្ញៀវ) | យ៉ាងហោច ៨០% | ១ |
| | ចំនួនពាក្យបណ្តឹងដែលមានកម្មវត្ថុទាក់ទងនឹងសុវត្ថិភាព ភ្ញៀវទេសចរទទួលបានក្នុងមួយឆ្នាំៗ | តិចជាង១០ | ១ |
| | ភាគរយនៃអ្នកបើករថយន្តឈ្នួល ម៉ូតូឌុប រ៉ឺម៉កកង់បីដែលមានឯកសណ្ឋាន | យ៉ាងហោច ៥០% | ១ |

| | | | |
|---|---|---|---|
| | តើមានការគិតគូរឲ្យមានជាចំណតសំរាប់ (រថយន្ត ម៉ូតូ កង់) នៅតាមវិថីសំខាន់ៗនៃទីក្រុង និងវិថីលក់ម្ហូបអាហារដែរឬទេ? | មាន-មិនមាន | ១ |
| | តើមានការគិតគូរលើចំណតសំរាប់ថ្ងៃគូ និងថ្ងៃសេស នៅតាមវិថីសំខាន់ៗនៃទីក្រុងដែរឬទេ? | មាន-មិនមាន | ១ |
| | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងបរិស្ថាន | មាន-មិនមាន | ១ |
| **៣៣-S3** សូចនាករលម្អិតនៃសកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើស | ការអនុវត្តវិធានការភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព | មាន-មិនមាន | ២ |
| | ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពដែលមានបណ្ណសរសើរពីក្រសួងមហាផ្ទៃ | យ៉ាងហោច ៥០% | ២ |
| **៣៤-S4** សូចនាករលម្អិតនៃវិធានសុវត្ថិភាពទេសចរណ៍ | វត្តមានជំរុញអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ | មាន-មិនមាន | ១ |
| | ការប្រឡងប្រណាំង ជំរុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍របស់បេក្ខភាព(ទទួលបានវិញ្ញាបនបត្រ) | មាន-មិនមាន | ១ |
| **៣៥-S5** សូចនាករលម្អិតនៃស្លាកយីហោពាណិជ្ជកម្ម និងស្លាកយីហោអាជីវកម្មនៅក្នុងទីក្រុង | យន្តការនៃការរៀបចំ និងគ្រប់គ្រងស្លាកយីហោពាណិជ្ជកម្មប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ | មាន-មិនមាន | ១ |
| | វិធានការជំរុញដល់អាជីវកម្មឱ្យគោរពទៅតាមបទដ្ឋាន និងការណែនាំរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃស្លាកយីហោអាជីវកម្ម | មាន-មិនមាន | ១ |
| | វិធានការទប់ស្កាត់ការដាក់តាំងស្លាកយីហោអាជីវកម្ម ឬស្លាកយីហោពាណិជ្ជកម្មអំពីគ្រឿងស្រវឹង និងថ្នាំជក់នៅជិតសាលារៀន និងវត្តអារាម | យ៉ាងហោចចម្ងាយ ៥០០ ម៉ែត្រ ពីសាលារៀន និងវត្តអារាម | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៥**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១៩** | | សរុប | ២១ |

## ៧.សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ (មាន៦សូចនាករលម្អិត)

| សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **៣៦-T1** សូចនាករលម្អិតនៃហេដ្ឋារចនាសម្ព័ន្ធទីក្រុង | តើមានផ្លូវថ្នល់ (ផ្លូវកៅស៊ូ ផ្លូវបេតុង) គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោច ៥០% នៃប្រវែងផ្លូវក្នុងក្រុងសរុប | ១ |
| | តើមានមតេយ្យសាលា ឬសាលាបឋមសិក្សាគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | ៥០០ម៉ែត្រពីទីប្រជុំជន | ១ |
| | តើមានអនុវិទ្យាល័យគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | ១០០០ម៉ែត្រពីទីប្រជុំជន | ១ |
| | តើមានវិទ្យាល័យគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | ១៥០០ម៉ែត្រពីទីប្រជុំជន | ១ |
| | តើមានសួនកំសាន្តសំរាប់កុមារគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោចណាស់ ១០% នៃតំបន់សាងសង់បាន | ១ |
| | តើមានទីតាំងសំរាប់លេងកីឡាគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោច ១០%នៃតំបន់សាងសង់បាន | ១ |
| | កំពង់ផែទេសចរណ៍ ឬចំណតរថយន្តទេសចរណ៍ដែលមាននៅក្នុងក្រុង/ខណ្ឌ | មាន-មិនមាន | ១ |
| **៣៧-T2** សូចនាករលម្អិតនៃប្លង់មេសម្រាប់ការអភិវឌ្ឍទេសចរណ៍ | តើមានផែនការមេ/ផែនការអភិវឌ្ឍទេសចរណ៍ដែរឬទេ? | មាន-មិនមាន | ២ |
| | តើមានផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ ដែរឬទេ? | មាន-មិនមាន | ១ |
| **៣៨-T3** សូចនាករលម្អិតនៃមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ | តើមានមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍នៅតាមតំបន់ទេសចរណ៍សំខាន់ៗគ្រប់គ្រាន់ដែរឬទេ? | គ្រប់គ្រាន់-មិនគ្រប់គ្រាន់ | ២ |
| | តើមានផែនទីទេសចរណ៍របស់ក្រុង/ខណ្ឌដែរឬទេ? | មាន-មិនមាន | ១ |
| | តើមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការផ្សព្វផ្សាយតំបន់ទេសចរណ៍ក្នុងក្រុង/ខណ្ឌដែរឬទេ? | មាន-មិនមាន | ១ |
| **៣៩-T4** សូចនាករលម្អិតនៃទីតាំងលក់ទំនិញ | តើមានមជ្ឈមណ្ឌលពាណិជ្ជកម្ម (Shopping center) នៅក្នុងទីក្រុងដែរឬទេ? | យ៉ាងហោច ១ | ១ |
| | តើមានផ្សាររាត្រីនៅក្នុងទីក្រុងដែរឬទេ? | យ៉ាងហោច ១ | ១ |
| | ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះការស្វាគមន៍រាក់ទាក់របស់ប្រជាជនមូលដ្ឋាន។ | យ៉ាងហោច ៧០% | ១ |

| | | | |
|---|---|---|---|
| ៤០-**T5** សូចនាករលម្អិតនៃកម្រិតភាពពេញចិត្តរបស់ភ្ញៀវទេសចរ | ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះភាពស្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍។ | យ៉ាងហោច ៧០% | ១ |
| | ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះការតុបតែងលំអនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍។ | យ៉ាងហោច ៧០% | ១ |
| ៤១-**T6** សូចនាករលម្អិតនៃការរៀបចំវិថីលក់ម្ហូបអាហារ ( Food Street ) និងការពង្រឹងគុណភាពតូបលក់ម្ហូបអាហារ (Street Food) នៅតាមក្រុង/ខណ្ឌ និងទីប្រជុំជននានា | តើមានវិថីលក់ម្ហូបអាហារ ( Food Street ) នៅក្នុងទីក្រុងដែរឬទេ ? | យ៉ាងហោច ១ | ១ |
| | ភាគរយនៃតូបលក់ម្ហូបអាហារ (Street Food) ដែលមានលិខិតបញ្ជាក់អនាម័យពីក្រសួង ឬមន្ទីរសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធ | យ៉ាងហោច ៥០% | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៦**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១៩** | | **សរុប** | **២១** |

## II. យន្តការនៃការប្រឡងប្រណាំងទីក្រុងស្អាត

ការប្រើប្រាស់តារាងវាយតម្លៃ គឺផ្អែកលើការប្រៀបធៀបរវាងលក្ខណវិនិច្ឆ័យខុសៗគ្នានៃការប្រឡងប្រណាំង**ទីក្រុងស្អាត** ដែលបានរៀបរាប់ខាងលើ ។

ការវាយតម្លៃ គឺជាគោលទុកសម្រាប់ធ្វើការវាស់វែងអំពីកម្រិតរបស់លក្ខណវិនិច្ឆ័យរបស់ទីក្រុងនីមួយៗ ថាតើលក្ខណវិនិច្ឆ័យទាំងនោះបានបំពេញលក្ខខណ្ឌនៃការប្រឡងប្រណាំងដែរឬទេ។

តារាងវាយតម្លៃនឹងអនុញ្ញាតឱ្យយើងធ្វើចំណាត់ថ្នាក់នៃទីក្រុង-ខណ្ឌជ័យលាភីទៅតាមកម្រិតពិន្ទុដែលទទួលបាន។ ស្លាកសញ្ញា (Logo) ៣ប្រភេទនឹងត្រូវផ្តល់ជូនជាអនុគមន៍ទៅនឹងចំនួនពិន្ទុដែលទទួលបាន។ ប្រភេទនៃស្លាកសញ្ញា (Logo) ឬរង្វាន់ នឹងត្រូវកំណត់ដោយគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។ ឧទាហរណ៍នៃការចែកជូនស្លាកសញ្ញា (Logo) ឬរង្វាន់ ៖

ស្លាកសញ្ញាផ្កាវំដួល **៣ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបានពិន្ទុចន្លោះ **៩០ និង ១២០** ពិន្ទុ (យ៉ាងហោចណាស់ស្មើនឹង៧៥% នៃចំនួនពិន្ទុសរុប)

ស្លាកសញ្ញាផ្កាវំដួល **២ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុចន្លោះ **៧២ និង ៨៩ ពិន្ទុ** (យ៉ាងហោចណាស់ស្មើនឹង៦០% នៃចំនួនពិន្ទុសរុប)

ស្លាកសញ្ញាផ្កាវំដួល **១ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុចន្លោះ **៤៨ និង ៧១ ពិន្ទុ** (យ៉ាងហោចណាស់ស្មើនឹង៤០% នៃចំនួនពិន្ទុសរុប)

## III. ដំណើរការនៃការប្រឡងប្រណាំង

- **ដំណាក់កាលទី១** ៖ ទីក្រុង-ខណ្ឌបេក្ខភាពទាំងអស់ត្រូវចូលរួមការប្រឡងប្រណាំងដោយកាតព្វកិច្ច ដោយធ្វើការដាក់ពាក្យស្នើសុំចូលរួមប្រឡងប្រណាំងទីក្រុងស្អាតមកកាន់គណៈកម្មាធិការជាតិវាតម្លៃទីក្រុងស្អាត (គ.ជ.វ.ទ.) ឬដាក់ពាក្យស្នើសុំតាមប្រព័ន្ធអនឡាញតាមរយៈគេហទំព័ររបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត www.cambodiacleancity.gov.kh។
- **ដំណាក់កាលទី២** ៖ ទីក្រុង-ខណ្ឌបេក្ខភាពត្រូវរៀបចំបំពេញឯកសារយោងទៅតាមលក្ខណវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត និងផ្ញើមកកាន់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត (គ.ជ.វ.ទ.) ដើម្បីធ្វើការពិនិត្យ និងវាយតម្លៃ។ បន្ទាប់មក គ.ជ.វ.ទ.រៀបចំក្រុមការងារ និងកម្មវិធីចុះពិនិត្យដល់ទីកន្លែងផ្ទាល់របស់ទីក្រុង-ខណ្ឌបេក្ខភាព ហើយកម្មវិធីចុះពិនិត្យនេះធ្វើឡើងក្នុងគោលបំណងធ្វើការ វិនិច្ឆ័យទីក្រុង-ខណ្ឌដោយយោងទៅលើតារាងវាយតម្លៃ។ ការត្រួតពិនិត្យនេះអាចធ្វើឡើងដោយការចុះទៅផ្ទាល់ដល់ទីរមណីយដ្ឋាន និងកន្លែងសាធារណៈផ្សេងៗរបស់ទីក្រុង-ខណ្ឌ និងធ្វើការសម្ភាសន៍ជាមួយអាជ្ញាធរក្រុង-ខណ្ឌ និងអាជ្ញាធរពាក់ព័ន្ធក្នុងការបង្ហាញភស្តុតាងផ្សេងៗ។
- **ដំណាក់កាលទី៣** ៖ ប្រកាសជ័យលាភីនៃការប្រកួតយោងតាមចំនួនលក្ខណវិនិច្ឆ័យដែលទីក្រុង-ខណ្ឌបានបំពេញ។ ចំពោះទីក្រុងដែលទទួលបានពិន្ទុទាប (មិនជាប់ចំណាត់ថ្នាក់) អាចទទួលបានការប្រឹក្សានិងផ្តល់យោបល់បន្ថែមទៀតពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត (គ.ជ.វ.ទ.) ដើម្បីឱ្យពួកគាត់អាចបំពេញលក្ខណវិនិច្ឆ័យដែលខ្វះខាត និងអាចក្លាយជាជ័យលាភីសម្រាប់ការប្រឡងប្រណាំងក្រោយៗទៀត។
- **ដំណាក់កាលទី៤** ៖ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត (គ.ជ.វ.ទ.) នឹងធ្វើការរៀចំពិធីប្រគល់ស្លាកសញ្ញាជាផ្លូវការដល់ក្រុង-ខណ្ឌដែលបានទទួលជ័យលាភី។ ទីក្រុង-ខណ្ឌជ័យលាភីអាចទទួលបានចំណាត់ថ្នាក់ទៅតាមពិន្ទុដែលខ្លួនបំពេញបាន។

<u>**កំណត់សម្គាល់ ៖**</u>

- **ពេលវេលានៃការប្រកួត**
  - ការប្រឡងប្រណាំងអាចនឹងត្រូវបានរៀបចំរៀងរាល់៣ឆ្នាំម្តង
  - ទីក្រុងជ័យលាភីនឹងអាចទទួលបានស្លាកសញ្ញាផ្ការំដួលដែលមានសុពលភាពសម្រាប់រយៈពេល៣ឆ្នាំ។
- **គណៈកម្មាធិការវាយតម្លៃ**
  - គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតត្រូវតែមានអធិបតេយ្យភាពក្នុងការផ្តល់ និងដកហូតស្លាកសញ្ញា និងត្រូវមាននីតិវិធីដំណើរការច្បាស់លាស់ ។
  - គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតមានសិទ្ធិស្វយ័តធ្វើការកែប្រែ និងធ្វើបច្ចុប្បន្នភាពលើស្តង់ដាទីក្រុងស្អាតដើម្បីឱ្យស្របតាមការវិវត្តន៍ និងរីកចំរើនជាក់ស្តែងរបស់ទីក្រុង-ខណ្ឌនាពេលអនាគត។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ទីក្រុងស្អាត ត្រូវផ្តើមចេញពីយើងទាំងអស់គ្នា

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
លេខៈ ០០២.សសរ.គជវទ.

ថ្ងៃ ចន្ទ ៦ រោច ខែ បុស្ស ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសូចនាករ និងលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជា
## ប្រធានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- លិខិតលេខ ២៦៩ សជណ.ពទ. ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ដីឡូត៍លេខ ៣A ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ១៦ ៧៣៨ ៤០៣ ទូរសារ: +៨៥៥ ២៣ ៨៨៥ ០១៨

# សម្រេច

**ប្រការ ១._**

ត្រូវបានកែសម្រួលសូចនាករ និងលក្ខណវិនិច្ឆ័យនៃ **ស្តង់ដាទីក្រុងស្អាត** តាមតម្រូវការចាំបាច់ និងការវិវត្តជាក់ស្តែងនៃចលនាប្រឡងប្រណាំងទីក្រុងស្អាតនៅកម្ពុជា ។

សូចនាករ និងលក្ខណវិនិច្ឆ័យនៃ **ស្តង់ដាទីក្រុងស្អាត** ដែលត្រូវបានកែសម្រួលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ ២._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣._**

អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋានវាយតម្លៃទីក្រុងស្អាត ប្រធាននាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញចលនាប្រឡងប្រណាំង ប្រធានក្រុមការងារវាយតម្លៃទីក្រុងស្អាតថ្នាក់រាជធានី ខេត្ត និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០០២ សសរ.គជវទ ចុះថ្ងៃចន្ទ ៦រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ត្រូវនឹងថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១

# ស្តីពី "ការកែសម្រួលសូចនាករ និងលក្ខណាវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត"

**សេចក្តីផ្តើម**

ការកែសម្រួលសូចនាករលម្អិត និងលក្ខណវិនិច្ឆ័យ នៃស្តង់ដាទីក្រុងស្អាត គឺផ្អែកលើអភិក្រម ចំនួន ០២ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់តាមការវិវត្តជាក់ស្តែងនៃចលនាប្រឡងប្រណាំងទីក្រុងស្អាត មានដូចខាងក្រោម៖

- អភិក្រមទី ០១ : ត្រូវបានកែសម្រួលលើខ្លឹមសារនៃសូចនាករគោលចំនួន **០២** និងដកចេញនូវលក្ខណវិនិច្ឆ័យចំនួន **០៣** និងជំនួសមកវិញនូវលក្ខណវិនិច្ឆ័យចំនួន **០២**
- អភិក្រមទី ០២ : បន្ថែមនូវសូចនាករលម្អិតចំនួន **០៨** និងលក្ខណវិនិច្ឆ័យចំនួន **៣**

ស្តង់ដាទីក្រុងស្អាត (ចាស់) មានចំនួន **០៧** សូចនាករគោល **៣៣** សូចនាករលម្អិត និង លក្ខណវិនិច្ឆ័យចំនួន **៧៧** ស្មើនឹង **៧៧ ពិន្ទុ** ។

បន្ទាប់ពីបានកែសម្រួលសូចនាករ និងលក្ខណវិនិច្ឆ័យ ស្តង់ដាទីក្រុងស្អាតបច្ចុប្បន្ន មាន ចំនួន **០៧** សូចនាករគោល **៤១** សូចនាករលម្អិត និង **១១៣** លក្ខណវិនិច្ឆ័យ (**ស្មើនឹង ១២០ ពិន្ទុ** ) ។

សូចនាករលម្អិត លក្ខណវិនិច្ឆ័យ និងពិន្ទុដែលត្រូវបានកែសម្រួលថ្មីមានដូចខាងក្រោម៖

- បន្ថែម **១** លក្ខណវិនិច្ឆ័យក្នុងសូចនាករគោលនៃការរៀបចំ និងការគ្រប់គ្រងបរិស្ថាន៖ ឱ្យពិន្ទុលើ **១** លក្ខណវិនិច្ឆ័យ
- បន្ថែម **៧** លក្ខណវិនិច្ឆ័យ ក្នុងសូចនាករនៃភាពស្អាត៖ ឱ្យពិន្ទុចំនួន **៩** លើ **៧** លក្ខណវិនិច្ឆ័យ (លក្ខណវិនិច្ឆ័យដែលទទួលបាន **០២** ពិន្ទុ មានចំនួន **០២** លក្ខណវិនិច្ឆ័យ)
- បន្ថែម **៣** លក្ខណវិនិច្ឆ័យ ក្នុងសូចនាករគោលនៃការគ្រប់គ្រងសំណល់៖ ឱ្យពិន្ទុចំនួន **៣** លើ **៣**លក្ខណវិនិច្ឆ័យ
- បន្ថែម **១** សូចនាករលម្អិត និង **៣** លក្ខណវិនិច្ឆ័យ ក្នុងសូចនាករគោលនៃបញ្ជ្រាបការយល់ដឹង៖ ឱ្យពិន្ទុចំនួន **៣** លើ **៣** លក្ខណវិនិច្ឆ័យ
- បន្ថែម **៦** សូចនាករលម្អិត និង **១៤** លក្ខណវិនិច្ឆ័យ ក្នុងសូចនាករគោលនៃតំបន់បៃតង និង ខ្សែក្រវាត់បៃតង ៖ ឱ្យពិន្ទុចំនួន **១៥** លើ **១៤** លក្ខណវិនិច្ឆ័យ (លក្ខណវិនិច្ឆ័យដែលទទួលបាន **០២** ពិន្ទុ មានចំនួន **០១** លក្ខណវិនិច្ឆ័យ)
- បន្ថែម **២** សូចនាករលម្អិត និង **៨** លក្ខណវិនិច្ឆ័យ ក្នុងសូចនាករគោលនៃសុវត្ថិភាពសុខភាព សាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង ៖ ឱ្យពិន្ទុចំនួន **១០** លើ **៨** លក្ខណវិនិច្ឆ័យ និង (លក្ខណវិនិច្ឆ័យដែលទទួលបាន **០២** ពិន្ទុមានចំនួន **០២** លក្ខណវិនិច្ឆ័យ)
- បន្ថែម **១** សូចនាករលម្អិត និង **៧** លក្ខណវិនិច្ឆ័យ ក្នុងសូចនាកគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ ៖ ឱ្យពិន្ទុចំនួន **៩** លើ **៧** លក្ខណវិនិច្ឆ័យ (លក្ខណវិនិច្ឆ័យដែលទទួលបាន **០២** ពិន្ទុ មាន **០២** លក្ខណវិនិច្ឆ័យ) ។

## I. តារាងសូចនាករថ្មីដែលបានកែសម្រួល និងបន្ថែម

### ១. សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន (មាន១សូចនាករលម្អិត)

| សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **៤-E4** សូចនាករលម្អិតនៃគុណភាពខ្យល់ | វិធានការដែលទាក់ទងទៅនឹងបរិស្ថានគ្មានផ្សែងបារី | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលម្អិត ៖ ១**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១** | | **សរុប** | ១ |

### ២. សូចនាករគោលនៃភាពស្អាត (មាន៣សូចនាករលម្អិត)

| សូចនាករគោលនៃភាពស្អាត | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **៩-P1** សូចនាករលម្អិតនៃភាពស្អាតនៅទីកន្លែងសាធារណៈ | ភាពស្អាតនៅតាមសាលារៀន | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមវត្តអារាម | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមផ្សារ | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមរោងចក្រ | មាន-មិនមាន | ១ |
| **១០-P2** សូចនាករលម្អិតនៃភាពស្អាតនៅតាមបង្គន់សាធារណៈ | បង្គន់សាធារណៈទាំងនោះជាកម្មវត្ថុនៃការថែរក្សា និងសម្អាតយ៉ាងទៀងទាត់ | យ៉ាងហោចណាស់ ៤ដងក្នុង១ថ្ងៃ | ២ |
| **១១-P3** សូចនាករលម្អិតនៃភាពស្អាតនៅតាមគោលដៅទេសចរណ៍ និងសម្បទាទេសចរណ៍ (សារមន្ទីរ ប្រាសាទ សួនកំសាន្ត ឆ្នេរ) | មានបង្គន់សាធារណៈនៅតាមគោលដៅទេសចរណ៍ (រមណីយដ្ឋាន និងសម្បទាទេសចរណ៍) | យ៉ាងហោចណាស់ ៥០% | ១ |
| | ភាគរយនៃភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ដែលបានចូលរួមអនុវត្តយុទ្ធនាការ “ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ស្អាត” | មាន-មិនមាន | ២ |
| - **ចំនួនសូចនាករលម្អិត ៖ ៣**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ៧** | | **សរុប** | ៩ |

### ៣. សូចនាករគោលនៃការគ្រប់គ្រងសំណល់ (មាន២សូចនាករលម្អិត)

| សូចនាករគោលនៃការគ្រប់គ្រងសំណល់ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **១៨-D4** សូចនាករលម្អិតនៃការស្តុក និងការធ្វើប្រព្រឹត្តកម្មលើសំណល់រឹង | ទីកន្លែងកែច្នៃសំណល់រឹង ដោយរដ្ឋ ឬឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល ។ល។ | មាន-មិនមាន | ១ |
| **១៩-D5** សូចនាករលម្អិតនៃការបែងចែកសំណល់រឹង | ការបំពាក់ធុងសំរាមដែលមានការបែងចែកប្រភេទសំរាម(ទីតាំងសាធារណៈ លំនៅឋានប្រជាពលរដ្ឋ។ល។) | មាន-មិនមាន | ១ |
| | រថយន្តប្រមូលសំរាមដែលមានការបែងចែកប្រភេទសំរាម | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលម្អិត ៖ ២**<br>- **ចំនួនលក្ខណៈវិនិច្ឆ័យ ៖ ៣** | | **សរុប** | **៣** |

### ៤. សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង (មាន១សូចនាករលម្អិត)

| សូចនករគោលនៃការបញ្ជ្រាបការយល់ដឹង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **២៣-I4** សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់កម្មករ-កម្មការិនីរោងចក្រ ឬសហគ្រាស | សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់កម្មករ-កម្មការិនីរោងចក្រ ឬសហគ្រាស | មាន-មិនមាន | ១ |
| | តើសកម្មភាពបញ្ជ្រាបការយល់ដឹងទាំងនេះធ្វើឡើងញឹកញាប់ដែរឬទេ? | យ៉ាងហោច ២ដងក្នុង១ឆ្នាំ | ១ |
| | មធ្យោបាយផ្តល់ព័ត៌មានអំពីបរិស្ថាន (បដាព័ត៌មាន ខិតប័ណ្ណផ្សព្វផ្សាយ ។ល។) | មាន-មិនមាន | ១ |
| - **ចំនួនសូនាករលម្អិត ៖ ១**<br>- **ចំនួនលក្ខណៈវិនិច្ឆ័យ ៖ ៣** | | **សរុប** | **៣** |

### ៥. សូចនាករគោលនៃតំបន់បៃតង និងខ្សែក្រវាត់បៃតង(មាន៦សូចនាករលម្អិត)

| សូចនករគោលនៃតំបន់បៃតង និងខ្សែក្រវាត់បៃតង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **២៤-V1** សូចនាករលម្អិតនៃការបង្កើត និងបែងចែកតំបន់បៃតង | ភាគរយតំបន់បៃតងធៀបនឹងផ្ទៃក្រឡាទីក្រុងទាំងមូល | ធំជាង ៥% | ២ |
| | សួនទេសចរណ៍នៅក្នុងក្រុង-ខណ្ឌ ឬតំបន់ជុំវិញ | មាន-មិនមាន | ១ |
| **២៥-V2** សូចនាករលម្អិតនៃការថែទាំ និងរៀបចំតំបន់បៃតង | ភាពញឹកញាប់ក្នុងការរៀបចំកម្មវិធីដាំដើមឈើ | យ៉ាងហោច ៤ដងក្នុង១ឆ្នាំ | ១ |

| | | | |
|---|---|---|---|
| **២៧-V4** សូចនាករលម្អិតនៃការរៀបចំទីតាំងលក់ផលិតផលក្នុងស្រុក | ផ្សារ ឬផ្សាររាត្រី ឬហាងដែលលក់ផលិតផលក្នុងស្រុក | មាន-មិនមាន | ១ |
| | មានការតាំងពិព័រណ៍អំពីផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| **២៨-V5** សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងអំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ប្រតិបត្តិករទេសចរណ៍អំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់សាធារណជនអំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ទេសចរជាតិ និងអន្តរជាតិពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង១ឆ្នាំ | ១ |
| **២៩-V6** សូចនាករលម្អិតនៃការរៀបចំខ្សែក្រវាត់បៃតង | ដៃគូសហប្រតិបត្តិការ (ដូចជា អង្គការជាតិ អន្តរជាតិ រដ្ឋាភិបាល ផ្នែកឯកជន សហគមន៍មូលដ្ឋាន ។ល។) ក្នុងការរៀបចំខ្សែក្រវាត់បៃតងនៅតាមគោលដៅទេសចរណ៍ និងតំបន់ជុំវិញទីក្រុង | មាន-មិនមាន | ១ |
| | បណ្តាញអ្នកប្រមូលទិញ ឬអន្តរការី ដើម្បីជំរុញឱ្យមានការប្រើប្រាស់ផលិតផលក្នុងស្រុក | មាន-មិនមាន | ១ |
| | សមាគម ឬសហគមន៍កសិកម្ម និងសិប្បកម្ម ដែលមានការផ្គត់ផ្គង់សម្រាប់វិស័យទេសចរណ៍ | មាន-មិនមាន | ១ |
| | ដៃគូសហប្រតិបត្តិការក្នុងការរៀបចំឧទ្យានកសិ-ទេសចរណ៍នៅតាមគោលដៅតំបន់ជុំវិញទីក្រុង | មាន-មិនមាន | ១ |
| **៣០-V7** សូចនាករលម្អិតនៃការជំរុញការប្រើប្រាស់និងផលិតផលិតផលក្នុងស្រុក | វិធានការជំរុញនិងលើកទឹកចិត្តដល់អ្នកប្រើប្រាស់ផលិតផលក្នុងស្រុក(ពិសេសសម្រាប់ប្រតិបត្តិករទេសចរណ៍) | មាន-មិនមាន | ១ |
| | វិធានការជំរុញនិងលើកទឹកចិត្តដល់អ្នកផលិតផលិតផលក្នុងស្រុកដែលផ្គត់ផ្គង់វិស័យ ទេសចរណ៍ | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលម្អិត ៖ ៦**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១៤** | | សរុប | ១៥ |

៦. <u>សូចនាករគោលនៃសុវត្ថិភាពសុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង</u> (មាន <u>៤សូចនាករលម្អិត)</u>

| សូចនាករគោលនៃសុវត្ថិភាពសុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **៣២-S2** សូចនាករលម្អិតនៃសន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងបរិស្ថាន | មាន-មិនមាន | ១ |
| **៣៣-S3** សូចនាករលម្អិតនៃសកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើស | ការអនុវត្តវិធានការភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព | មាន-មិនមាន | ២ |
| | ភូមិ- ឃុំ-សង្កាត់មានសុវត្ថិភាពដែលមានបណ្ណសរសើរពីក្រសួងមហាផ្ទៃ | យ៉ាងហោច ៥០% | ២ |
| **៣៤-S4** សូចនាករលម្អិតនៃវិធានសុវត្ថិភាពទេសចរណ៍ | វត្តមានជំរុញវិធានសុវត្ថិភាពទេសចរណ៍នៅក្នុងក្រុង/ខណ្ឌ | មាន-មិនមាន | ១ |
| | ការប្រឡងប្រណាំង ជំរុញការអនុវត្តវិធានសុវត្ថិភាព ទេសចរណ៍របស់បេក្ខភាព(ទទួលបានវិញ្ញាបនបត្រ) | មាន-មិនមាន | ១ |
| **៣៥-S5** សូចនាករលម្អិតនៃស្លាកយីហោពាណិជ្ជកម្ម និងស្លាកយីហោអាជីវកម្មនៅក្នុងទីក្រុង | យន្តការនៃការរៀបចំ និងគ្រប់គ្រងស្លាកយីហោពាណិជ្ជកម្មប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ | មាន-មិនមាន | ១ |
| | វិធានការជំរុញដល់អាជីវកម្មឱ្យគោរពទៅតាមបទដ្ឋាន និងការណែនាំរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃស្លាកយីហោអាជីវកម្ម | មាន-មិនមាន | ១ |
| | វិធានការទប់ស្កាត់ការដាក់តាំងស្លាកយីហោអាជីវកម្ម ឬស្លាកយីហោពាណិជ្ជកម្មអំពីគ្រឿងស្រវឹង និងថ្នាំជក់នៅជិតសាលារៀន និងវត្តអារាម | យ៉ាងហោចចម្ងាយ ៥០០ ម៉ែត្រ ពីសាលារៀន និងវត្តអារាម | ១ |
| **- ចំនួនសូចនាករលម្អិត ៖ ៤**<br>**- ចំនួនលក្ខណវិនិច្ឆ័យ ៖ ៨** | | **សរុប** | **១០** |

## ៧.សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ (មាន៤សូចនាករលម្អិត)

| សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **៣៦-T1** សូចនាករលម្អិតនៃហេដ្ឋារចនាសម្ព័ន្ធទីក្រុង | កំពង់ផែទេសចរណ៍ ឬចំណតរថយន្តទេសចរណ៍ដែលមាននៅក្នុងទីក្រុង | មាន-មិនមាន | ១ |
| **៣៧-T2** សូចនាករលម្អិតនៃប្លង់មេសម្រាប់ការអភិវឌ្ឍទេសចរណ៍ | តើមានផែនការមេ/ ផែនការអភិវឌ្ឍទេសចរណ៍ដែរឬទេ ? | មាន-មិនមាន | ២ |
| **៣៨-T3** សូចនាករលម្អិតនៃមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ | តើមានមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍នៅតាមតំបន់ទេសចរណ៍សំខាន់ៗគ្រប់គ្រាន់ដែរឬទេ ? | គ្រប់គ្រាន់-មិនគ្រប់គ្រាន់ | ២ |
| | តើមានផែនទីទេសចរណ៍របស់ក្រុង/ខណ្ឌដែរឬទេ ? | មាន-មិនមាន | ១ |
| | តើមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការផ្សព្វផ្សាយតំបន់ទេសចរណ៍ក្នុងក្រុងដែរឬទេ ? | មាន-មិនមាន | ១ |
| **៤១-T6** សូចនាករលម្អិតនៃការរៀបចំវិថីលក់ម្ហូបអាហារ (Food Street) និងការពង្រឹងគុណភាពតូបលក់ម្ហូបអាហារ (Street Food) នៅតាមក្រុង/ខណ្ឌ និងទីប្រជុំជននានា | តើមានវិថីលក់ម្ហូបអាហារ (Food Street) នៅក្នុងទីក្រុងដែរឬទេ ? | យ៉ាងហោច ១ | ១ |
| | ភាគរយនៃតូបលក់ម្ហូបអាហារ (Street Food) ដែលមានលិខិតបញ្ជាក់អនាម័យពីក្រសួង ឬមន្ទីរសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធ | យ៉ាងហោច ៥០% | ១ |
| - **ចំនួនសូចនាករលម្អិត ៖ ៤**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ៧** | | **សរុប** | ៩ |

## II. យន្តការនៃការប្រឡងប្រណាំងទីក្រុងស្អាត

ការប្រើប្រាស់តារាងវាយតម្លៃ គឺផ្អែកលើការប្រៀបធៀបរវាងលក្ខណវិនិច្ឆ័យខុសៗគ្នានៃការប្រឡងប្រណាំងទីក្រុងស្អាត ដែលបានរៀបរាប់ខាងលើ ។

ការវាយតម្លៃ គឺជាគោលទុកសម្រាប់ធ្វើការវាស់វែងអំពីកម្រិតរបស់លក្ខណវិនិច្ឆ័យរបស់ទីក្រុងនីមួយៗ ថាតើលក្ខណវិនិច្ឆ័យទាំងនោះបានបំពេញលក្ខខណ្ឌនៃការប្រឡងប្រណាំងដែរឬទេ។

តារាងវាយតម្លៃនឹងអនុញ្ញាតឱ្យយើងធ្វើចំណាត់ថ្នាក់នៃទីក្រុង-ខណ្ឌជ័យលាភីទៅតាមកម្រិតពិន្ទុដែលទទួលបាន។ ស្លាកសញ្ញា (Logo) ៣ប្រភេទនឹងត្រូវផ្តល់ជូនជាអនុគមន៍ទៅនឹងចំនួនពិន្ទុដែលទទួលបាន។ ប្រភេទនៃស្លាកសញ្ញា (Logo) ឬរង្វាន់ នឹងត្រូវកំណត់ដោយ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។ ឧទាហរណ៍នៃការចែកជូនស្លាកសញ្ញា (Logo) ឬរង្វាន់ ៖

ស្លាកសញ្ញាផ្ការំដួល **៣ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបានពិន្ទុចន្លោះ **៩០ និង ១២០** ពិន្ទុ (យ៉ាងហោចណាស់ស្មើនឹង៧៥% នៃចំនួនពិន្ទុសរុប)

ស្លាកសញ្ញាផ្ការំដួល **២ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុចន្លោះ **៧២ និង ៨៩** ពិន្ទុ (យ៉ាងហោចណាស់ស្មើនឹង៦០% នៃចំនួនពិន្ទុសរុប)

ស្លាកសញ្ញាផ្ការំដួល **១ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុចន្លោះ **៤៨ និង ៧១** ពិន្ទុ (យ៉ាងហោចណាស់ស្មើនឹង៤០% នៃចំនួនពិន្ទុសរុប)